**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៤៧២ ប្រក. កសក

# ប្រកាស

## ស្តីពី

## ការកំណត់តំបន់ផ្ទះជំនឺរូកត្រចៀកខៀវ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងការកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- យោងលទ្ធផលវិភាគលេខ៤០៣/១៥ វ.ជ.ស.ប ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ និងលេខ៤១១ ៤១២ ៤១៣/១៥ វ.ជ.ស.ប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ របស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់តំបន់ជំងឺជ្រូកត្រចៀកខៀវ(PRRS)ចំនួន០៤(បួន)កន្លែង ស្ថិតនៅ៖

១-ភូមិឬស្សីលក ឃុំឬស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប

២-ភូមិជីគៀកនិងភូមិជ្រៃជើង ឃុំគៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប

៣-ភូមិបាក់ផ្កា ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប

៤-ភូមិគោកឬស្សីត្បូង ឃុំដានរ៉ុង ស្រុកសូទ្រនិគម ខេត្តសៀមរាប។

**ប្រការ ២.-**

នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ត្រូវចាត់វិធានការបសុពេទ្យនៅតំបន់ផ្ទុះជំងឺជ្រូកត្រចៀកខៀវដែលមានចែងក្នុងប្រការ១ នៃប្រកាសនេះ ដូចខាងក្រោម៖

- ចាត់វិធានការជីវសុវត្ថិភាពនៅតាមកសិដ្ឋាន កន្លែងចិញ្ចឹមជ្រូក ក្នុងតំបន់ផ្ទុះជំងឺ

- ផ្អាកជាបណ្តោះអាសន្នការទិញ ការលក់ ឬការដឹកជញ្ជូនជ្រូករស់ចូល ចេញ ឬឆ្លងកាត់ក្នុងរង្វង់កាំប្រវែង០១(មួយ)គីឡូម៉ែត្រ ពីចំណុចផ្ចិតនៃតំបន់ផ្ទុះជំងឺ។ តំបន់នេះជាតំបន់ត្រូវការពារ តាមដាន សិក្សាស្រាវជ្រាវក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ និងត្រូវត្រួតពិនិត្យឃ្លាំមើលចលនាជ្រូករស់ជាប្រចាំក្នុងរង្វង់កាំប្រវែង១០(ដប់) គីឡូម៉ែត្រពីចំណុចផ្ចិតនៃតំបន់ផ្ទុះជំងឺ។

**ប្រការ ៣.-**

ក្នុងករណីម្ចាស់កសិដ្ឋានឬប្រជាពលរដ្ឋចង់ចិញ្ចឹមជ្រូកសាច់ឬជ្រូកពូជនៅក្នុងតំបន់ផ្ទុះជំងឺជ្រូកត្រចៀកខៀវ ត្រូវរាយការណ៍ជូនបសុពេទ្យ ដើម្បីចាត់វិធានការជីវសុវត្ថិភាពនិងសម្លាប់មេរោគស្របតាមវិធានបច្ចេកទេសជាមុនសិន រហូតដល់តំបន់នេះត្រូវបានប្រកាសរំសាយជំងឺជ្រូកត្រចៀកខៀវ ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាថ្មី។

**ប្រការ ៤.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋាន-កិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយក-ដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ប្រធានមន្ទីរកសិកម្មខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត វេង សាខុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងបរិស្ថាន
-ក្រសួងយុត្តិធម៌
-ក្រសួងសុខាភិបាល
-ក្រសួងព័ត៌មាន
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តសៀមរាប
" ដើម្បីជូនជ្រាប "
-ដូចប្រការ៥
-ឯកសារ កាលប្បវត្តិ